**សំណួរ**

**តើនៅពេលណា កិច្ចព្រមព្រៀងចូលជាធរមាន សម្រាប់រដ្ឋមួយ** (entry into force of treaty)?

**ចម្លើយ**

កិច្ចព្រមព្រៀង ជាទូទៅ ចូលជាធរមាន ទើបចងកាតព្វកិច្ច ដល់រដ្ឋដែលជាភាគី។ ក្នុងន័យនេះ វាជាចំណុចសំខាន់ ដើម្បីដឹងថា តើកិច្ចព្រមព្រៀងចូលជាធរមានសម្រាប់រដ្ឋណាមួយ នៅពេលណា ដើម្បីអាចនឹងចោទថារដ្ឋបានបំពាន ឬមិនបំពានកាតព្វកិច្ចដែលពាក់ព័ន្ធណាមួយ ក្នុងកិច្ចព្រមព្រៀងនោះ?។

អនុលោមតាមគោលការណ៍ព្រមព្រៀង (principle of consent) ជាគោលការណ៍ចំបង នៃច្បាប់អន្តរជាតិ ដែលមិនចាប់បង្ខំ រដ្ឋឲ្យចូលជាភាគី ការចូលជាធរមាននៃកិច្ចព្រមព្រៀងណាមួយ វាផ្អែកទៅតាមខ្លឹមសារ ដែលភាគីបានព្រមព្រៀងចុះក្នុងកិច្ចព្រមព្រៀងនោះ។ ការចូលជាធរមាន នៃកិច្ចព្រមព្រៀងទ្វេភាគី អាចខុសពីកិច្ចព្រមព្រៀងពហុភាគី។ មាត្រា ២៤ នៃសន្ធិសញ្ញា ស្តីពី បត្យាប័នរវាងកម្ពុជា និងថៃ ឆ្នាំ ១៩៩៨ ៖ *សន្ធិសញ្ញានេះ នឹងចូលជាធរមាន ៣០ថ្ងៃ បន្ទាប់ពីការផ្លាស់ប្តូរនូវឯកសារផ្តល់សច្ចាប័ន*។ កតិកាសញ្ញា ស្តីពី សិទ្ធិស៊ីវិល និងនយោបាយ ឆ្នាំ ១៩៦៧ មាត្រា ៤៩(២) ចែងថា៖ *សម្រាប់រដ្ឋណាមួយ ដែលផ្តល់សច្ចាប័ន កតិកាសញ្ញានេះ ឬទទួលយក ក្រោយពេលការតម្កល់ឯកសារផ្តល់សច្ចាប័នទី៣៥ ...កតិកាសញ្ញានេះ នឹងចូលជាធរមានក្នុងរយៈពេល៣ខែ ក្រោយពីកាលបរិច្ឆេទនៃការតម្កល់ឯកសារចូលជាភាគី*។[1]

កម្ពុជា មិនមែនក្នុងចំណោមរដ្ឋទាំង ៣៥ ដែលនាំឲ្យកតិកាសញ្ញា ចូលជាធរមានជាដំបូងទេ (មើលកថាខ័ណ្ឌខាងលើ)។ ក្រោយចូលជាធរមាន រាជរដ្ឋាភិបាលកម្ពុជា បានស្នើសុំឲ្យសភាយល់ព្រមឲ្យកម្ពុជាក្លាយជាភាគី។ ក្រោយពីសភាឯកភាព រដ្ឋាភិបាល តាមរយៈក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នឹងបញ្ជូនលិខិតូបករណ៍ ទៅតម្កល់នូវអគ្គលេខាធិការដ្ឋានអង្គការសហប្រជាជាតិ ហើយកតិកានឹងចូលជាធរមាន៣ខែ ក្រោយពីកាលបរិច្ឆេទតម្កល់។ ឧទាហរណ៍ ថ្ងៃតម្កល់គឺ ១៥ មេសា ឆ្នាំ ២០១០ ថ្ងៃចូលជាធរមាន (បីខែបន្ទាប់) គឺ ១៥ កក្កដា ឆ្នាំ ២០១០។ ចាប់ថ្ងៃនេះ កាតព្វកិច្ចចាប់ផ្តើមចងដល់កម្ពុជា។ កម្ពុជា នឹងត្រូវបានចោទថាបំពាន ក្នុងករណីមិនបានធ្វើតាមការទាមទារ របស់កតិកាសញ្ញា ចាប់ពីថ្ងៃនោះតទៅ។

---

[1] For each State ratifying the present Covenant or acceding to it after the deposit of the thirty-fifth instrument of ratification or instrument of accession, the present Covenant shall enter into force three months after the date of the deposit of its own instrument of ratification or instrument of accession.

ជាការកត់សំគាល់ គេមិនអាចចេះតែចោទថា រដ្ឋណាមួយបំពានកាតព្វកិច្ច ដោយមិនបានគិតដល់ពេលចូលជាធរមាននៃសន្ធិសញ្ញា ឬកិច្ចព្រមព្រៀងសម្រាប់រដ្ឋនោះទេ។ វាលើកលែងតែកាតព្វកិច្ចពាក់ព័ន្ធ ជាវិធានទំនៀមទម្លាប់អន្តរជាតិ ចងជាកាតព្វកិច្ចដល់រដ្ឋ ដោយឯករាជ្យពីសន្ធិសញ្ញា និងមុនកិច្ចព្រមព្រៀង ចូលជាធរមានទៀត។ សូមមើលបន្ថែមសំណួរចម្លើយ ស្តីពី វិធានទំនៀមទម្លាប់អន្តរជាតិ (Customary International Law)។

**Further Reading**: UN, the entry into force of bilateral investment treaties (BITs), 2006; UNICEF, Definition of key terms used in the UN treaty collection, https://www.unicef.org/french/crc/files/Definitions.pdf; United Nations, *Vienna Convention on the Law of Treaties*, 23 May 1969, United Nations, Treaty Series, vol. 1155, p. 331, available at: https://www.refworld.org/docid/3ae6b3a10.html [accessed 18 September 2019]